ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៧ លេខ ៦០ ត្រីមាសទី ០៣ ឆ្នាំ ២០១៧

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារមាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៩-០៧-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៧១៧/៥៨១ ស្តីពី ការប្រោសព្រះរាជទានគោរមងារឯកឧត្តម **ទ្រៀ ជាញ់** ជា សម្តេចពិជ័យសេនា **ទ្រៀ ជាញ់** ៦១៩៨

២៩-០៧-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៧១៧/៥៩១ ស្តីពី ការតែងតាំង ឯកឧត្តម **សរ ចន្ទារិទ្ធ** ជា នាយរងព្រះរាជលេខាធិការដ្ឋាន **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងសេរីភាព សេចក្តីថ្លៃថ្នូ និងសុភមង្គល មានឋានៈស្មើ រដ្ឋលេខាធិការ ៦១៩៩

០២-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៥៩៣ ស្តីពី ការតែងតាំងសមាសភាពថ្នាក់ដឹកនាំក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ៦២០០

០២-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៥៩៥ ស្តីពី ការតែងតាំង ឯកឧត្តម **ស ថាវី** ជា អភិបាល នៃគណៈអភិបាល ខេត្តឧត្តរមានជ័យ សម្រាប់អាណត្តិទី ២ ក្នុងដែនសមត្ថកិច្ចដដែល ៦២០២

០២-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៥៩៦ ស្តីពី ការតែងតាំងឯកឧត្តម **ឈួរ ចំន្ទឌ្យ៉ែន** ជាអភិបាល នៃគណៈអភិបាល ខេត្តកំពង់ឆ្នាំង សម្រាប់អាណត្តិទី ២ ក្នុងដែនសមត្ថកិច្ចដដែល ៦២០៣

០៤-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៥៩៧ ស្តីពី ការតែងតាំងឯកឧត្តម **ហួត ឃាងវេង** ជា អនុរដ្ឋលេខាធិការ នៃក្រសួងព័ត៌មាន ៦២០៤

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

០៣-០៨-២០១៧ -អនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្តីពី ការបង្កើតគណៈកម្មាធិការជាតិ នៃសមាគមន៍ច្បាប់អាស៊ានកម្ពុជា ៦២០៥

០៣-០៨-២០១៧ -អនុក្រឹត្យលេខ ១២៥ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៣៩,៣៧១៦ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៧ គ្រួសារ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ ៦២០៨

២៨-០៧-២០១៧	-អនុក្រឹត្យលេខ ៧៦៨ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច តម្លើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ	៦២១៣
២៨-០៧-២០១៧	-អនុក្រឹត្យលេខ ៧៦៩ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ	៦២១៥
២៨-០៧-២០១៧	-អនុក្រឹត្យលេខ ៧៧០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៦២១៧
៣១-០៧-២០១៧	-អនុក្រឹត្យលេខ ៧៧១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៦២១៨
៣១-០៧-២០១៧	-អនុក្រឹត្យលេខ ៧៧២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ	៦២១៩
០១-០៨-២០១៧	-អនុក្រឹត្យលេខ ៧៧៤ អនក្រ.តត ស្តីពី ការជូនមេដាយសហាមេត្រី	៦២២១
០១-០៨-២០១៧	-អនុក្រឹត្យលេខ ៧៧៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ	៦២២៣

២.សេចក្តីសម្រេច

០១-០៨-២០១៧	-សេចក្តីសម្រេចលេខ ៦០ សសរ ស្តីពី ការបំពេញក្របខ័ណ្ឌថ្មី	៦២៥៦
០១-០៨-២០១៧	-សេចក្តីសម្រេចលេខ ៦១ សសរ ស្តីពី ការបំពេញបន្ថែមអនុប្រធាន និងសមាជិកគណៈកម្មការ សម្រាប់សិក្សា និងរៀបចំសាងសង់វិមានអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ និងការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា	៦២៥៧

III.ការងារបណ្តាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៧-០៧-២០១៧	-ប្រកាសរួមលេខ ៦៤៨ សហវ.ប្រក ស្តីពី ការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	៦២៥៩

ព្រះរាជក្រឹត្យ

នស/រកត/០៧១៧/ ៤៥១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ភូហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីតិបុណ្យ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។
- បានទ្រង់យល់ឯកឧត្តម ទៀ បាញ់ ជាអ្នកដឹកនាំជំនើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ បានចូលរួមជួយដឹកនាំប្រជាជាតិកម្ពុជា តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចូលរួមកសាងប្រព័ន្ធច្បាប់សម្រាប់ប្រើប្រាស់ជាឧត្តមប្រយោជន៍ដល់សង្គមជាតិ ទទួលបាននូវសន្តិភាព ស្ថិរភាពឯកភាពជាតិ ការអភិវឌ្ឍជាតិលើគ្រប់វិស័យ ការពារលទ្ធិប្រជាធិបតេយ្យ ការពារជាតិ មានស្ថិរភាពសន្តិសុខសង្គមបានល្អប្រសើរ និងមានកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងរក្សាបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី ក្រោមការដឹកនាំជំណាញ់ដ៏ឆ្លាតវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។
- បានទ្រង់យល់ ឯកឧត្តម ទៀ បាញ់ ជាអ្នកដឹកនាំជំនើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ មានស្វាមីភក្តិចំពោះរាជបល្ល័ង្ក ការពារ និងគោរពព្រះពុទ្ធសាសនា ចូលរួមការពារនិរន្តរភាពជាតិនិយមនៃព្រះរាជាណាចក្រកម្ពុជា។

ប្រោសព្រះរាជទានគោរមងារ

ឯកឧត្តម ទៀ បាញ់

ជា

សម្តេចពិជ័យសេនា ទៀ បាញ់

ថ្ងៃសៅរ៍ ១០រោច ខែភាទ ឆ្នាំ ៤៥៤
ត្រូវនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៧
សម្តេចចៅហ្វាវាំងវង្សជ័យ អធិបតីស្រីការ គង់ សំអ
ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ព្រះរាជក្រឹត្យ

នស/រកត/០៧១៧/ ៥៩១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភ្ជាមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងួហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង

ឯកឧត្តម **សរ ចន្ធរិទ្ធី**

ជា

នាយរងព្រះរាជលេខាធិការដ្ឋាន
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះឥសរជាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
មានឋានៈស្មើ រដ្ឋលេខាធិការ

ព្រះហស្តលេខា និងព្រះរាជលញ្ឆកម
នរោត្តម សីហមុនី

ភាសា. ១២០០០.៦០០

ធ្វើនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧

លេខ:៤៩៩ ស.ណ
សំណៅដើមអានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/ ៥៩៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភ្ជាមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៨ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជានិងមាត្រា៨ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៨ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើត រាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៥៩២ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ក្រាស់បន្ទាប់

មាត្រា១.-

តែងតាំងសមាសភាពថ្នាក់ដឹកនាំក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ៖

១-ឯកឧត្តមបណ្ឌិតសភាចារ្យ	**អូន ព័ន្ធមុនីរ័ត្ន**	ប្រធាន
២-ឯកឧត្តមបណ្ឌិតសភាចារ្យ	**ហាង់ ជួន ណារ៉ុន**	អនុប្រធាន
៣-ឯកឧត្តមបណ្ឌិតសភាចារ្យ	**សុខ ទូច**	អនុប្រធានប្រចាំការ។

មាត្រា២.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣.-

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៧
ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បន្ទាប់
ប្រមុខរដ្ឋស្តីទី

ព.រ.ស.១៧០៤.៦០២

ហត្ថលេខា និងព្រះរាជលញ្ឆកម
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខ: ៥៩៥ ស.ណ
សំណៅដើមមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៨១៧/ ៥៩៥

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងួហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ស ថាវី** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ១ ជាអភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៧
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆកម
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

ចាងណ. ១០០០ម.ណ.

លេខ: ៥៩២ ស.ណ
សំណៅដើមមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរៈរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរៈជនា សម្ព្រះហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរៈស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

នស/រកត/០៨១៧/ ៥៩៦

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ឈូ រ ច័ន្ទឌឿន** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៣ ជាអភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១៧
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆកម
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

ចាវ.ណ.១៧/០៨.៦០៥

លេខ: ៥៩៦ ស.ណ
សំណៅដើមមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៥១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភ្ជាប់ជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តម **ហួត ឃាចវេច** ជា **អនុរដ្ឋលេខាធិការ** នៃក្រសួងព័ត៌មាន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆកម
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខ: ១០២ ស.ណ
សំណៅដើមមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ចម្លងត្រឹមត្រូវ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១.២.៤.៧.ន្ត្រ.ហ

អនុក្រឹត្យ
ស្តីពី
ការបង្កើតគណៈកម្មាធិការជាតិនៃសហគមន៍ច្បាប់អាស៊ានកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- យោងលិខិតលេខ ៣៤៤ សជណ.អស៊ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរួមរបស់ប្រធានតុលាការកំពូល និងប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

សម្រេច
ជំពូក ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១._គោលបំណង

អនុក្រឹត្យនេះមានគោលបំណង ដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យច្បាប់នៅក្នុងបណ្តាប្រទេសអាស៊ាន។

មាត្រា ២._គោលដៅ

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការក្នុងវិស័យច្បាប់ដើម្បីរួមចំណែក

ធានាការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ និងវិនិយោគិន ក្នុងតំបន់អាស៊ាន និងទាក់ទាញវិនិយោគបរទេស។

ជំពូក ២
គណៈកម្មាធិការជាតិនៃសមាគមន៍ច្បាប់អាស៊ានកម្ពុជា

មាត្រា ៣._ការបង្កើត

ត្រូវបានបង្កើតគណៈកម្មាធិការជាតិនៃសមាគមន៍ច្បាប់អាស៊ានកម្ពុជាដែលហៅកាត់ថា"គ.ស.ច្ប.អ.ស៊.ក" ដែលមានប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានគណៈកម្មាធិការ និងមានអនុប្រធានអចិន្ត្រៃយ៍ សមាជិក និងលេខាធិការ តាមការសម្រេចរបស់ប្រធានគណៈកម្មាធិការ។

មាត្រា ៤._ការប្រព្រឹត្តទៅរបស់ គ.ស.ច្ប.អ.ស៊.ក

ការប្រព្រឹត្តទៅរបស់ គ.ស.ច្ប.អ.ស៊.ក ស្ថិតក្រោមបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន។

ជំពូក ៣
សកម្មភាព និងរចនាសម្ព័ន្ធ

មាត្រា ៥._សកម្មភាព និងតួនាទី

គណៈកម្មាធិការជាតិនៃសមាគមន៍ច្បាប់អាស៊ានកម្ពុជាមានតួនាទី និងភារកិច្ច៖

- បង្កើត និងអនុវត្តស្របតាមបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន
- ចូលរួមប្រជុំប្រជុំ និងធ្វើសកម្មភាពស្របតាមលក្ខន្តិកៈរបស់សមាគមន៍ច្បាប់អាស៊ាន
- ចូលរួមបង្ហាញអំពីទិដ្ឋភាពច្បាប់របស់កម្ពុជាលើឆាកអន្តរជាតិ
- ធ្វើសហប្រតិបត្តិការលើទិដ្ឋភាពច្បាប់របស់ប្រទេសកម្ពុជាជាមួយអ្នកច្បាប់នៃបណ្តាប្រទេសអាស៊ាន ដទៃទៀត ដើម្បីជួយជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កម្ពុជា និងទាក់ទាញវិនិយោគិន និង
- ទទួលរៀបចំព្រឹត្តិការណ៍នៃកិច្ចប្រជុំសមាគមន៍ច្បាប់អាស៊ាន តាមវេន ដោយសម្របសម្រួលជាមួយនឹងកិច្ចប្រជុំក្រុមប្រឹក្សាប្រធានតុលាការកំពូលអាស៊ាន ដោយសហការជាមួយតុលាការកំពូល។

មាត្រា ៦._រចនាសម្ព័ន្ធ និងត្រា

គណៈកម្មាធិការជាតិនេះអាចបង្កើតក្រុមការងារ ស្របតាមរចនាសម្ព័ន្ធការងាររបស់សមាគមន៍ច្បាប់អាស៊ាន។

គណៈកម្មាធិការជាតិនេះមានត្រាប្រើប្រាស់សម្រាប់អនុវត្តការងាររបស់ខ្លួន តាមការកំណត់របស់ប្រធានគណៈកម្មាធិការជាតិនេះ។

គណៈកម្មាធិការជាតិនេះអាចមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាសេនាធិការ។

មាត្រា ៧._ថវិកា

គណៈកម្មាធិការជាតិនេះទទួលថវិកាឧបត្ថម្ភពីកញ្ចប់ថវិកាពិសេសរបស់រាជរដ្ឋាភិបាលសម្រាប់ដំណើរ

ការរដ្ឋបាល ការរៀបចំកិច្ចប្រជុំសមាគមន៍ច្បាប់អាស៊ានតាមវេន និងការចូលរួមប្រជុំជាអន្តរជាតិ ។
គណៈកម្មាធិការជាតិនេះត្រូវលើកគម្រោងចំណាយរបស់ខ្លួនជូនរាជរដ្ឋាភិបាល។

ជំពូក ៤
អវសានប្បញ្ញត្តិ

មាត្រា ៨._ការទុកជានិរាកណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៩._ស្ថាប័ន និងបុគ្គលទទួលបន្ទុកអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ៣ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៧
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
ដើម្បីចុះហត្ថលេខា
ប្រធានតុលាការកំពូល ប្រធានគណៈមេធាវី

ឌិត មុន្នី **សួន ឌីសាល**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី

ការកាត់ដីទំហំ ៣៩,៣៧១៦ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៧ គ្រួសារ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៧៤៩/១៦ល.ស ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- លិខិតលេខ ៣០២៥ ដនស/អសក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៧ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ ៤៧៧២ កសក ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា ១ : ត្រូវបានកាត់ផ្ទៃដីទំហំ **៣៩,៣៧១៦ ហិកតា** ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៧គ្រួសារ ទំហំ **៣៧,០០០៣ ហិកតា** និងផ្ទៃដីទំហំ **២,៣៧១៣ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិស្រែលាវ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ២ : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ដើម្បីធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ នៅភូមិស្រែលាវ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ។

មាត្រា ៣ : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពតត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ០៧ ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ជូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ ២០១៧ស្តីពីការ
កាត់ដីចំហំ ៣៩.៣៧១៦ ហិកតា នៅភូមិស្រែលាវ ឃុំត្រពាំងភ្នាង ស្រុកឈូក ខេត្តកំពត ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បី
ធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៧ គ្រួសារ កាន់កាប់ដាំដុះជាក់ស្តែង
និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



ចំណុច	Y_PROJ	X_PROJ
1	1200875	418825
2	1200871	418848
3	1200841	419018
4	1200833	419174
5	1200848	419179
6	1200879	419188
7	1200910	419195
8	1200960	419206
9	1200995	419215
10	1201029	419223
11	1201073	419234
12	1201125	419247
13	1201180	419257
14	1201252	419270
15	1201302	419276
16	1201378	419293
17	1201450	419304
18	1201537	419319
19	1201599	419331
20	1201590	419295
21	1201634	419264
22	1201676	419119
23	1201663	419045
24	1201651	419052
25	1201610	418924
26	1201593	418889
27	1201541	418860
28	1201407	418834
29	1201319	418579
30	1201264	418625
31	1201117	418732
32	1200989	418783
33	1200883	418821

សញ្ញាសម្គាល់

- ភូមិ
- ឃុំ
- ដីភ្នំ
- ព្រំប្រទល់ដីកាត់ចេញចំនួនសរុប ៣៩.៣៧១៦ ហិកតា
- ចំនុចគោល
- ការធ្វើប្រទានកម្មដីជូនប្រជាពលរដ្ឋចំនួន ៣៧.០០០៣ ហិកតា
- រក្សាទុកដីសាធារណៈរបស់រដ្ឋចំនួន ២.៣៧១៣ ហិកតា
- ស្ទឹង
- ផ្លូវ

ទិន្នន័យគម្របព្រៃឈើ២០០២

- ព្រៃស្រាង
- ព្រៃពាក់កណ្តាលស្រាង
- ព្រៃល្បោះ
- ដីគ្មានគម្របព្រៃ

Coordinate System Projection UTM
Zone 48N Map Datum:WGS84

N

មាត្រដ្ឋាន 1:8,000

0 105 210 420 630 840 Meters

ឯកសារ ១ ១ ១

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...១២៤.អនក្រ.បក...ចុះថ្ងៃទី.០៣...ខែ.តុលា...ឆ្នាំ ២០១៧ ស្តីពីការ
កាត់ដីចំនួន ៣៩.៣៧១៦ ហិកតា នៅភូមិស្រែឈូ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ចេញពីគម្រោងព្រៃឈើឆ្នាំ២០០២ ដើម្បី
ធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៧ គ្រួសារ កាន់កាប់ដាំដុះជាក់ស្តែង
និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



ចំណុច	Y_PROJ	X_PROJ
1	1200875	418825
2	1200871	418848
3	1200841	419018
4	1200833	419174
5	1200848	419179
6	1200879	419188
7	1200910	419195
8	1200960	419206
9	1200995	419215
10	1201029	419223
11	1201073	419234
12	1201125	419247
13	1201180	419257
14	1201252	419270
15	1201302	419276
16	1201378	419293
17	1201450	419304
18	1201537	419319
19	1201599	419331
20	1201590	419295
21	1201634	419264
22	1201676	419119
23	1201663	419045
24	1201651	419052
25	1201610	418924
26	1201593	418889
27	1201541	418860
28	1201407	418834
29	1201319	418579
30	1201264	418625
31	1201117	418732
32	1200989	418783
33	1200883	418821

N
មាត្រដ្ឋាន 1:10,000

ធ្វើការវាស់វែងដោយប្រើឧបករណ៍ GPS MAP 62s
ថ្ងៃ...ខែ..តុលា....ឆ្នាំ២០១៦
អ្នកវាស់វែង
ស៊ីក ចាន់
លេខ៧២១០.ស.ភ.ភ

បានឃើញ និងពិនិត្យត្រឹមត្រូវ
កំពត.ថ្ងៃទី...១៨...ខែ...តុលា...ឆ្នាំ២០១៦
ប្រធានមន្ទីរគ្រប់គ្រងដីធ្លី និងរៀបចំនយោបាយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត
យ៉ិន ភុណ្ឌ
លោក.ស.ធ.ម.ខ.ខ.ស

បានឃើញ និងឯកភាព
កំពត.ថ្ងៃទី..១២...ខែ...តុលា...ឆ្នាំ២០១៦
អភិបាលខេត្ត នឹងជា
ស្នងការរងទទួលបន្ទុកការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត
ចាន់ ចេស្តា

Coordinate System Projection UTM

ឯកសារ ១ ០ ០ ០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:.ណ.ឯ.ផ.សនក្រ.ត.ត

អនុក្រឹត្យ
ស្តីពី
ការផ្ទេរការកិច្ច តម្លើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៨/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ផ្ទេរការកិច្ចលោក **សុន តារា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ពីអភិបាលរង នៃគណៈអភិបាលខេត្តកោះកុង ឲ្យទៅបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ។

មាត្រា ២ : តម្លើងឋានន្តរស័ក្តិលោក **អ៊ុក ភ័ណ្ឌា** ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ១ ទៅឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ៤ នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងតែងតាំងមុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តកោះកុង។

មាត្រា ៣ : តែងតាំងមន្ត្រីរាជការចំនួន ០២រូប ឲ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈខេត្តអភិបាលខេត្តកោះកុង ដូចមានរាយនាមខាងក្រោម:

១-លោក **ស្រេង ហុង** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងមុខងារសាធារណៈ ឲ្យកាន់មុខតំណែងជាអភិបាលរងខេត្ត

២-លោក **សុខ សុទ្ធី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ឲ្យកាន់មុខតំណែងជាអភិបាលរងខេត្ត។

មាត្រា ៤ : ក្នុងរយៈពេលនៃការមកបំពេញភារកិច្ចថ្មីនេះលោក **អ៊ុក រ៉ាត្នា** និងលោក **ស្រេង ហុង** ត្រូវដាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

មាត្រា ៥ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:០៧.ឯ.ន.ស.អនក្រ.៥៥

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៨/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងលោក **ឆុង គន្ធា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ឲ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តព្រៃវែង។

មាត្រា ២ : តម្លើងឋានន្តរស័ក្តិ និងតែងតាំងមុខតំណែងមន្ត្រីរាជការចំនួន ០២រូប ជាអភិបាលរង នៃគណៈអភិបាលខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម:

១-លោក **សួន សុម៉ាលីន** ពីឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ២ ទៅឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ និងតែងតាំងមុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្ត

២-លោក **ហេង ចាគគង់** ពីឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ១ ទៅឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតែងតាំងមុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្ត។

មាត្រា ៣ : ក្នុងរយៈពេលនៃការមកបំពេញភារកិច្ចថ្មីនេះលោក **ហេង ចាគគង់** ត្រូវជាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៨៧.២០.រ.ន.ក្រ.ឥ.ឥ

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងលោក **ហេម ពិសិដ្ឋ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ឲ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តស្វាយរៀង។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ធ្លាប់មាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២២២១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការនិងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ ៤៨៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : តែងតាំងលោក **ចាន់ មនោរម្យ** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយករង ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *រដ្ឋមន្ត្រីគ្រប់ ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:៧២.២០១.២២២.២៨

អនុក្រឹត្យ

ស្តីពីការជួនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនសប្បុរសជន និងមន្ត្រីរាជការចំនួន ១១ រូប ដែលបានលះបង់កម្លាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋានលើគ្រប់វិស័យ អោយមានការរីកចម្រើនគួរជាទីមោទនៈ ស្ថិតនៅក្នុងស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

១-ឯកឧត្តមឧត្តមសេនីយ៍ឯក	**ហ៊ូ សាគុណ**	អគ្គស្នងការរងនគរបាលជាតិ
២-លោកឧត្តមសេនីយ៍ឯក	**ឌ្យាច យ៉ីន**	អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន
៣-លោកឧត្តមសេនីយ៍ឯក	**ម៉ុន ថាវណ្ណ**	អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន
៤-លោកឧត្តមសេនីយ៍ទោ	**អ៊ុន សាវុធ**	អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន
៥-លោកឧត្តមសេនីយ៍ទោ	**គង់ សារ៉ី**	អនុប្រធានអង្គភាពតម្រួតបទបញ្ជា
៦-លោកឧត្តមសេនីយ៍ត្រី	**ទូ ហាត់**	អនុប្រធាននាយដ្ឋាននគរបាលការពារព្រំដែនទឹក
៧-លោក	**ឃុង គន្ធា**	អភិបាល នៃគណៈអភិបាលស្រុកស្វាយអន្ទរ
៨-លោក	**ខាន់ រក្សា**	សប្បុរសជននៅខេត្តព្រៃវែង

៩-លោក **ម៉ែ ជាជាកូរ៉ាត់**	សប្បុរសជននៅខេត្តព្រៃវែង
១០-លោក **សុខ លីហ្ស**	សប្បុរសជននៅខេត្តព្រៃវែង
១១-លោក **សាង ទិបុល**	សប្បុរសជននៅខេត្តព្រៃវែង

មាត្រា ២.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២.២.៤.២.ក.ត.ត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហាមេត្រី
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា ១. _ បំពាក់ **មេដាយសហាមេត្រី** តាមលំដាប់ថ្នាក់ ចំនួន ០៩គ្រឿង ជូនកងទ័ពប្រជាជនវៀតណាម ចំនួន ០៩រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយកងទ័ពជើងគោក កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយសហាមេត្រី ថ្នាក់ ធំបំផុត

១-	ឧត្តមសេនីយ៍ទោ	** វ៉ូ មិញ្ញលើង** VO MINH LOEUNG	មេបញ្ជាការយោធា យោធភូមិភាគទី៧ កងទ័ពប្រជាជនវៀតណាម
២-	ឧត្តមសេនីយ៍ទោ	**ផាន ង៉ាន់ឌី** PHAN VAN DY	មេបញ្ជាការយោធា យោធភូមិភាគទី៧ កងទ័ពប្រជាជនវៀតណាម
៣-	លោក	**ង្វៀន ម៉ាញ់ហ៊ុន** NGUYEN MANH HUNG	លេខាបក្សខេត្ត ប៊ិញធីន សាធារណៈរដ្ឋសង្គមនិយមវៀតណាម

ខ-មេដាយសហាមេត្រី ថ្នាក់ សេនា

១-	ឧត្តមសេនីយ៍ត្រី	**ផាន តិនតាយ** PHAN TANTAI	មេបញ្ជាការរងយោធា យោធភូមិភាគទី៧ កងទ័ពប្រជាជនវៀតណាម
២-	លោក	**ង្វៀន ង៉ុកហាយ** NGUYEN NGOC HAI	ប្រធានគណៈកម្មាធិការខេត្តប៊ិញធីនសាធារណៈរដ្ឋសង្គមនិយមវៀតណាម
៣-	វរសេនីយ៍ឯក	**ផាន កុងង្វាន** PHAN CONG NGON	មេបញ្ជាការយោធាខេត្ត ប៊ិញធីនសាធារណៈរដ្ឋសង្គមនិយមវៀតណាម

គ-មេដាយសហាមេត្រី ថ្នាក់ អស្សប្ញទ្ធិ

១-	វរសេនីយ៍ឯក	**ផាន ង៉ាន់ឡុង** PHAN VAN LONG	ប្រធាននយោបាយយោធាខេត្តប៊ិញធីនសាធារណៈរដ្ឋសង្គមនិយមវៀតណាម

២-	វរសេនីយ៍ឯក	**ត្រឹង ថាញ់ឌីក** TRAN THANH DUC	អនុប្រធានទីស្តីការ យោធាខេត្តបិញ្ញធីន
			សាធារណៈរដ្ឋសង្គមនិយមវៀតណាម
៣-	វរសេនីយ៍ឯក	**ឃាង់ ម៉ាន់ឡាំ** BACH VANLAM	ប្រធានការិយាល័យការបរទេស យោធភូមិភាគ
			ទី៧ កងទ័ពប្រជាជនវៀតណាម

មាត្រា ២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ មេបញ្ជាការកងទ័ពជើងគោក និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ឧត្តមក្រសួងសម្តេចនាយករដ្ឋមន្ត្រី
-ឧត្តមក្រសួងឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២.២.៤.២០ក្រ.ត.ត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.. បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ និងខេត្តកំពត ចំនួន ១០៦២ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ

១	លោក	ខៀវ	សុមនា	ប្រធានការិយាល័យ	មន្ទីរអប់រំ យុវជន និងកីឡា	ខេត្តកំពង់ស្ពឺ
២	លោក	ម៉ម	កុសល	អនុប្រធានការិយាល័យ	មន្ទីរអប់រំ យុវជន និងកីឡា	ខេត្តកំពង់ស្ពឺ
៣	លោក	យ៉ី	ថេង	អនុប្រធានការិយាល័យ	មន្ទីរអប់រំ យុវជន និងកីឡា	ខេត្តកំពង់ស្ពឺ
៤	លោក	មិន	ធន្ធដារ៉ា	នាយករង	សាលាគរុកោសល្យ	ខេត្តកំពង់ស្ពឺ
៥	លោកស្រី	ម៉ម	ណារ៉ុ	នាយិកា	សាលាបឋមសិក្សាអង្គសិរី	ក្រុងច្បារមន
៦	លោក	យ៉ីម	គ៉ីមសាន	នាយក	សាលាបឋមសិក្សាភូមិថ្មី	ក្រុងច្បារមន
៧	លោក	ឌុច	យ៉ុន	នាយក	សាលាបឋមសិក្សាភ្នំពិត	ស្រុកបរសេដ្ឋ
៨	លោក	ឃ	ឡារិន	នាយក	សាលាបឋមកាត់ភ្ជុក	ស្រុកបរសេដ្ឋ
៩	លោក	នាក់	សុវណ្ណ	នាយករង	វិទ្យាល័យបរសេដ្ឋ	ស្រុកបរសេដ្ឋ
១០	លោក	ម៉ែន	សុផាត	គណៈគ្រប់គ្រង	វិទ្យាល័យទ័ពមានជ័យ	ស្រុកគងពិសី

១១	លោកស្រី	ក៏ម	ស្រីណាន	នាយិកា	សាលាបឋមសិក្សាសែនទាវ	ស្រុកគងពិសី
១២	លោក	ឌៀប	គា	គណៈគ្រប់គ្រង	វិទ្យាល័យព្រះបិតាឯករាជ្យ	ស្រុកគងពិសី
១៣	លោក	ខេង	សុខរ៉ីម	នាយក	អនុវិទ្យាល័យបន្ទាយប្រណាក	ស្រុកឱរ៉ាល់
១៤	លោក	ឃួ	សំណាង	នាយករង	វិទ្យាល័យចាន់ថ្នាល	ស្រុកឧដុង្គ
១៥	លោក	ស៊ីម	សុវុត្ថា	នាយករង	សាលាបឋមសិក្សាវ៉ាំងចាស់	ស្រុកឧដុង្គ
១៦	លោក	ជា	ឆាយ	នាយករង	សាលាបឋមសិក្សាក្រាំងពញ្ញា	ស្រុកឧដុង្គ
១៧	លោក	ស្វាយ	ស៊ី	នាយក	សាលាបឋមសិក្សាពុទ្រា	ស្រុកភ្នំស្រួច
១៨	លោក	វណ្ណ	ម៉ាឌី	នាយក	សាលាបឋមសិក្សាត្រពាំងឱប	ស្រុកភ្នំស្រួច
១៩	លោក	ហោ	សាវុធ	នាយករង	វិទ្យាល័យត្រែងត្រយ៉ីង	ស្រុកភ្នំស្រួច
២០	លោក	សោម	នី	នាយក	វិទ្យាល័យឌីប៉ុក	ស្រុកសំរោងទង
២១	លោកស្រី	ប៉ុល	សុផន	នាយិកា	សាលាបឋមសិក្សាវល្លិ៍ស	ស្រុកសំរោងទង
២២	លោក	ស្ងួន	សុឃី	នាយក	សាលាបឋមសិក្សាកំណប់	ស្រុកសំរោងទង
២៣	លោក	ទូច	សុខុម	នាយក	សាលាបឋមសិក្សារលាំងឈ្លក	ស្រុកសំរោងទង
២៤	លោក	យ៉ីម	គ៏មហាច	ប្រធាន	ការិយាល័យអប់រំយុវជន និងកីឬា	ស្រុកថ្គង
២៥	លោក	ម៉ែក	សារិទ្ធ	មន្ត្រីរដ្ឋបាល	មន្ទីរអប់រំ យុវជន និងកីឬា	ខេត្តកំពង់ស្ពឺ
២៦	លោកស្រី	ទូច	ប៊ុណ្ណារិទ្ធ	មន្ត្រីរដ្ឋបាល	មន្ទីរអប់រំ យុវជន និងកីឬា	ខេត្តកំពង់ស្ពឺ
២៧	លោកស្រី	ឈុន	សុខុម	មន្ត្រីរដ្ឋបាល	មន្ទីរអប់រំ យុវជន និងកីឬា	ខេត្តកំពង់ស្ពឺ
២៨	លោកស្រី	សុទ្ធ	ស្រីនាង	មន្ត្រីរដ្ឋបាល	មន្ទីរអប់រំ យុវជន និងកីឬា	ខេត្តកំពង់ស្ពឺ
២៩	លោក	គុយ	ឈីម	មន្ត្រីរដ្ឋបាល	ការិយាល័យអប់រំ យុវជន និងកីឬា	ក្រុងច្បារមន
៣០	លោក	ស្ងរ	ហ្ស	មន្ត្រីរដ្ឋបាល	ការិយាល័យអប់រំ យុវជន និងកីឬា	ក្រុងច្បារមន
៣១	លោក	ឈីម	សាវរ៉ីយ៍	មន្ត្រីរដ្ឋបាល	សាលាបឋមសិក្សាម្រុំជើង	ក្រុងច្បារមន
៣២	លោក	វ៉ាន់	ឈឹន	មន្ត្រីរដ្ឋបាល	អនុវិទ្យាល័យមង្គលបពិត្រ	ស្រុកបរសេដ្ឋ
